គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កម្មវិធី

កិច្ចប្រជុំពិភាក្សាលើករណី ស្តីពី "ដំណោះស្រាយបញ្ហាពពោះជំនួស"

ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង ៨:១៥នាទី ព្រឹក**

**នៅ ទីស្តីការក្រសួងមហាផ្ទៃ សាលប្រជុំអគារ (A)**

| | | |
|---|---|---|
| -ម៉ោង ៨:០០ ដល់ ៨:១៥ | ៖ | សមាជិក-សមាជិកាអង្គប្រជុំអញ្ជើញដល់ |
| -ម៉ោង ៨:១៥ ដល់ ៨:៣០ | ៖ | -**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ អញ្ជើញដល់ និងបើកកិច្ចប្រជុំពិភាក្សា |
| -ម៉ោង ៨:៣០ ដល់ ៨:៤០ | ៖ | របាយការណ៍សង្ខេបដោយ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| -ម៉ោង ៨:៤០ ដល់ ១០:០០ | ៖ | មតិយោបល់របស់សមាជិកចូលរួម សម្របសម្រួលដោយ **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ |
| -ម៉ោង ១០ : ០០ | ៖ | មតិបូកសរុបបិទកម្មវិធីដោយ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ |

*(សូមរក្សាសិទ្ធកែប្រែ ក្នុងករណីចាំបាច់)*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខាធិការដ្ឋានរដ្ឋបាលសរុប

**កំណត់ហេតុ**

**កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីដំណោះស្រាយបញ្ហាពពោះជំនួស**

**សាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧**

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែកុម្ភៈ ថ្ងៃទីប្រាំពីរ វេលាម៉ោងដប់បួន និងសាបសិបនាទីរសៀល នៅសាលប្រជុំអគ្គលេខាធិ ការដ្ឋាន គ.ជ.ប.ជ បានបើកកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ ស្តីពី ដំណោះស្រាយបញ្ហាពពោះជំនួស ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម | កើត រិទ្ធ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| ២.លោកជំទាវ | ប៊ិន ពុទ្ធី | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី |
| ៣.ឯ.ឧ ឧ.ឯក | ចៅង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៤.លោក | តែ សុខា | ជំនួយការរដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ៥.ល.ជំ ឧ.ឯក | យក់ សុខា | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ៦.ឯ.ឧ ឧ.ឯក | យឹម វិរៈ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៧.លោកជំទាវ | រ៉ន សិរីលក្ខិណា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៨.ឯកឧត្តម | អ៊ិច ចាន់ណូរ៉ា | អគ្គនាយករង អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៩.ឯ.ឧ ឧ.ឯក | ប៉ុល ភិធេយ្យ | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ១០.លោក | សេង ហៀង | ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ១១.លោក | រស់ ពិសិដ្ឋ | ចៅក្រម សាលាដំបូងរាជធានីភ្នំពេញ |
| ១២.លោក វ.ឯក | ចាន់ កិត្តិឧម | ស្នងការរង នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ |
| ១៣.លោក | ណុប រដ្ឋា | ប្រធានការិយាល័យ ក្រសួងការបរទេស |
| ១៤.លោក វ.ឯក | កែវ ជា | នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |

១៥.ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ ចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ **គ.ជ.ប.ជ** បានមានមតិស្វាគមន៍យ៉ាងកក់ក្តៅ និងជ្រាលជ្រៅបំផុតដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនាពេលនេះ។

**លោកជំទាវ** មានប្រសាសន៍បន្តទៀតថា ដំណោះស្រាយបញ្ហាពពោះជំនួសនេះ យើងបានជួបប្រជុំពិភាក្សាគ្នាបានចំនួន ០៤លើករួចមកហើយ ដូចនេះកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីបញ្ហាពពោះជំនួសនាពេលនេះ ត្រូវរកដំណោះស្រាយឲ្យបានជ្រះស្រឡះនូវករណីដែលសេសសល់នៅក្នុងដៃ។

**មតិលោក រស់ ពិសិដ្ឋ** ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ បានរាយការណ៍ជូនជាសង្ខេបអំពីលទ្ធផលដែលបានអនុវត្តកន្លងមក យោងតាមឯកសារដែលបានសួរនាំរបស់ស្ត្រីជនជាតិអូស្ត្រាលី ថមមី(ជនសង្ស័យ) បញ្ជាក់ថា ចំនួនស្ត្រីខ្មែរដែលកំពុងពពោះជំនួសនោះគឺ មួយចំនួនបញ្ជាក់ទីលំនៅពុំបានត្រឹមត្រូវទេ តែមួយចំនួនទៀតមានទីលំនៅច្បាស់លាស់។ លោកបានបន្តទៀតថា ចំពោះការចោទប្រកាន់ជនសង្ស័យវិញគឺ យើងធ្វើការចោទ យោងតាមមាត្រា ៦៣២, ៣៣២ ដដែល តែការឃុំខ្លួនជនសង្ស័យនោះគឺ ជិតផុតកំណត់ នៃការឃុំខ្លួនបណ្តោះអាសន្នហើយ (បានឃុំខ្លួនថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦)រហូតមកដល់ថ្ងៃនេះគឺសល់តែប៉ុន្មានថ្ងៃទៀតប៉ុណ្ណោះ។ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ នីតិវិធីតុលាការ បន្តសួរនាំលើជនសង្ស័យ ថមមី ទៀត តែគាត់បានស្នើសុំដល់ស្ថានទូតអូស្ត្រាលីសិន។

**មតិលោក វរសេនីយ៍ឯក កែវ ឆា** ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន **នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ** ទាក់ទងនឹងក្រុមហ៊ុន ញូឡាយ ដែលជាក្រុមហ៊ុនមានជាប់ពាក់ព័ន្ធលើការជួលឲ្យស្ត្រីខ្មែរពពោះជំនួសនោះដែរ គឺការិយាល័យជំនាញ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ព្រមទាំងស្នងការដ្ឋាននគរបាលខេត្តកណ្តាល បានធ្វើការស៊ើបអង្កេតលើក្រុមហ៊ុន ញូឡាយ នោះ ក្តាប់បាន មុខសញ្ញាពាក់ព័ន្ធលើការជួលស្ត្រីខ្មែរ ឲ្យពពោះជំនួសនោះហើយ។

**ប្រសាសន៍ ឯកឧត្តម កើត រិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌** ខ្ញុំបានសង្កេតឃើញថាបញ្ហាពពោះជំនួសនេះមានភាពស្មុគស្មាញខ្លាំងណាស់។ ច្បាប់ពពោះជំនួសនៅកម្ពុជាយើង គឺពុំទាន់មានទេ ដូចនេះប្រសិនបើយើងអនុញ្ញាតឲ្យកូនដែលកើតចេញមកយកចេញទៅក្រៅប្រទេសទៀត វាជាការជំរុញឲ្យកើតមានកាន់តែច្រើនឡើងថែមទៀត។ យើងត្រូវបង្កើតចេញនូវគណៈកម្មការមួយក្នុងការបង្កើតច្បាប់ស្តីពីបញ្ហាពពោះជំនួសនេះឲ្យបានឆាប់កាន់តែល្អ។ ចំពោះករណីដែលកើតឡើងនាពេលកន្លងមកលើស្ត្រីខ្មែរ ដែលគេឲ្យពពោះជំនួសនោះ គឺសុទ្ធតែកើតឡើងចេញពីអំប្រុំយយ៉ុងរបស់គេទាំងអស់(មេជីវិត)។ ផ្អែកតាមក្របរដ្ឋប្បវេណី នៃព្រះរាជណាចក្រកម្ពុជាយើងយោងតាមមាត្រាមួយចំនួនដែលមាន ស្តីពីចំណងអាពាហ៍ពិពាហ៍(ប្តី ប្រពន្ធ )និងអំណាចមេបាវិញ គឺអាចដោះស្រាយបញ្ហាកើតឡើងកន្លងមកបានតាមផ្លូវច្បាប់ បញ្ហាពពោះជំនួសនេះ សម្រាប់អ្នកមានគ្រួសារ(ប្តី) គឺស្មុគស្មាញបន្តិច តែបើជាស្ត្រីមេម៉ាយ ឬនៅលីវ ងាយស្រួលក្នុងការដោះស្រាយ។

ចំណងអាពាហ៍ពិពាហ៍រវាងប្តី និងប្រពន្ធ និងអំណាចមេបា ក្រោយពេលសម្រាលកូនចេញមក ប្តីត្រូវធ្វើការផ្តាច់ចំណងបដិសេធកូនដោយការពពោះជំនួសចេញ ដោយប្រគល់កូននោះឲ្យគេ បដិសេធពុំទទួលស្គាល់ថាកូន

នោះជាកូនរបស់ខ្លួន។ ប៉ុន្តែកូននោះត្រូវផ្តល់សញ្ជាតិឲ្យគេ ២សញ្ជាតិ។ ដោយឡែកស្ត្រីពពោះជំនួសនោះនៅតែជាម្តាយរបស់កូននោះដដែល គឺមិនអាចផ្តាច់ចេញបានទេ។

ឯកឧត្តម បានមានប្រសាសន៍បន្តទៀតថា ដំណោះស្រាយរបស់យើងលើករណីសេសសល់ គួរធ្វើលើផ្នែកនយោបាយល្អប្រសើរជាង។ បើយើងធ្វើតាមផ្លូវច្បាប់វិញអ្នកជាប់ពាក់ព័ន្ធនៅមានបន្តរហូតលើកលែងតែកូនមួយគត់ដែលគ្មានទោស។ ដើម្បីទប់ស្កាត់កុំឲ្យកើតមានបន្តទៀតគឺ ត្រូវឲ្យក្រសួងសុខាភិបាលគ្រប់គ្រងឲ្យបានរឹងមាំលើផ្នែកឯកជន(គ្លីនីក) ការផ្តល់សំបុត្រកំណើតជាដើម។ ឯកឧត្តម បានជម្រាបជូន លោកជំទាវ ចំពោះស្ត្រីពពោះជំនួសដែលត្រូវជាម្តាយរបស់កូននោះ គឺគាត់មានសិទ្ធសាកសួរសុខទុក និងបញ្ហាផ្សេងៗទៀត នៅពេលកូននោះបានទៅរស់នៅក្រៅប្រទេសជាមួយអ្នកស្នើសុំ។

តាមច្បាប់ស្ត្រីពពោះ ពេលបង្កើតកូននោះចេញមក គឺជាម្តាយស្របច្បាប់ ដូចនេះទោះបីមានលិខិតស្នាមអ្វីក៏ដោយស្ត្រីនោះនៅតែជាម្តាយរបស់កូននោះដដែល។ ចំពោះករណីនេះ សូមឲ្យខាងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ត្រូវធ្វើកិច្ចការនេះ ដោយប្រុងប្រយ័ត្ន និងអនុវត្តឲ្យបានត្រឹមត្រូវ ជៀសវាងកុំឲ្យគេថា កម្ពុជាយើងជាទីផ្សារប្រកបរបរនេះ។

**ប្រសាសន៍ ឯកឧត្តម អ៊ុច ចាន់ណារ៉ា** អគ្គនាយករង នៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម បញ្ហាពពោះនេះ មានលក្ខណៈស្មុគស្មាញណាស់នៅកម្ពុជាយើង។ ប្រទេសមួយចំនួនលើពិភពលោក ប្រទេសខ្លះច្បាប់គេអនុញ្ញាត្តិ និងប្រទេសខ្លះ គេហាមឃាត់តែម្តង និងប្រទេសខ្លះទៀតគេថាធ្វើដោយលក្ខណៈមនុស្សធម៌។ ពីមុនប្រទេស ឥណ្ឌា នេប៉ាល់ ការពពោះជំនួសនេះ គេធ្វើជាលក្ខណៈពាណិជ្ជកម្ម តែក្រោយមកត្រូវបានហាមឃាត់ ។ នៅប្រទេសគេខ្លះស្ត្រីព ពោះជំនួសដោយបញ្ចូលមេជីវិត ពីបុរសផ្សេងក្តី ពេលគាត់កើតបានកូននោះមក គឺស្ត្រីនោះច្បាប់ទទួលស្គាល់ជាម្តាយរបស់កូននោះ ដោយស្របច្បាប់ទៀតផង។ ពាក់ព័ន្ធលើអ្នកស្នើសុំកូន គួរយកចិត្តទុកដាក់ភាពនៅលីវ និងភេទដូចគ្នា ។

**មតិ លោកឧត្តមសេនីយ៍ទោ សុខ វាសនា** ប្រធាននាយកដ្ឋានជនបរទេស មិនមែនអន្តោប្រវេសន៍ និងបច្ចេកវិទ្យា នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ពាក់ព័ន្ធករណីពពោះជំនួសដោយស្ត្រីខ្មែរ មុនកិច្ចប្រជុំពិភាក្សា ស្តីពីដំណោះស្រាយបញ្ហាពពោះជំនួស នាយកដ្ឋានបានផ្តល់ទិដ្ឋាការចេញបានចំនួន ២៦ នាក់ និងស្ត្រីជនជាតិថៃចំនួន០៧ នាក់ សរុបចំនួន ៣៣ នាក់ លើ៤សញ្ជាតិ:

+ក្មេងសញ្ជាតិ ចិន ១៤ នាក់ +ក្មេងសញ្ជាតិ ជប៉ុន ០៨ នាក់

+ក្មេងសញ្ជាតិ អាមេរិក ០៥ នាក់ -ក្មេងសញ្ជាតិ អូស្ត្រាលី ០៦ នាក់

ហើយស្ត្រីពពោះជំនួសនោះ សម្រាលកូននៅមន្ទីរពេទ្យសង់ត្រាលចំនួន ១៤ នាក់ មន្ទីរពេទ្យលុចចំនួន ១៤ នាក់ និងមន្ទីរពេទ្យផ្សេងៗចំនួន ០៥ នាក់ ។ ក្មេងទាំង ៣៣ នាក់ យើងបានផ្តល់ទិដ្ឋាការចេញអស់ហើយ ។ ប៉ុន្តែនៅពេលថ្មីៗកន្លងមកនេះ នាយកដ្ឋានជនបរទេស មិនមែនអន្តោប្រវេសន៍ និងបច្ចេកវិទ្យា បានទទួលពាក្យអ្នកស្នើសុំកូនចេញ ទៅប្រទេសគោលដៅចំនួន ០៤ ប្រទេស ដែលមានក្មេងចំនួន ១០ នាក់ ក្នុងនោះ រួមមានៈ

+ក្មេងសញ្ជាតិ កាណាដា ០១ នាក់ +ក្មេងសញ្ជាតិ ជប៉ុន ០១ នាក់

+ក្មេងសញ្ជាតិ អាមេរិក ០៥ នាក់ -ក្មេងសញ្ជាតិ អូស្ត្រាលី ០៣ នាក់

ចំនួនកូនទាំង១០នាក់ ដូចបានជម្រាបជូនខាងលើ គឺមានស្ត្រីខ្មែរ និងស្ត្រីជនជាតិថៃ ជាអ្នកពពោះជំនួស ។ចំពោះអ្នកស្នើសុំទាំងនោះ យើងបានទទួលការបញ្ជាក់លទ្ធផល DNA ពួកគាត់រួចហើយ។

**ប្រសាសន៍លោកជំទាវ ឧត្តមសេនីយ៍ឯក យក់ សុខា** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិច្បាប់ស្តីពី អន្តរការរវាងអ្នកសុំកូននិងស្ត្រីពពោះ នៅកម្ពុជាយើងពុំទាន់មានច្បាប់ចែងនៅឡើយទេ តែយើងត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងសុខាភិបាល ដោយយោងតាមមាត្រាទី១៤ និង១៥ នៃប្រកាសនោះ។

**មតិលោក ណុប រដ្ឋា** ប្រធានការិយាល័យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានឯកភាពនិងគាំទ្រ ការលើកឡើងរបស់ឯកឧត្តម **កើត រិទ្ធ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌។ សម្រាប់ស្ត្រីនៅលីវ និងកូននៅពេលធំធាត់ រស់នៅក្រៅប្រទេស តើយើងត្រូវធ្វើដូចម្តេចខ្លះ?

**ប្រសាសន៍លោកជំទាវ ជូ ប៊ុនអេង** : នៅពេលថ្មីៗនេះ ទទួលបានព័ត៌មានថា ស្ត្រីខ្មែរពពោះជំនួសចំនួន ៧ នាក់ មានអ្នកមកធ្វើពាក្យស្នើសុំយកកូនចេញទៅក្រៅប្រទេស ដូចជាៈ ប្រទេសអូស្ត្រាលី កាណាដា និងសហរដ្ឋអាមេរិក ។ដូច្នេះយើងពុំទាន់ដឹងថាតើនៅមានស្ត្រីពពោះជំនួសមានចំនួនប៉ុន្មាននាក់ទៀត? ពាក់ព័ន្ធស្ត្រី ១៨ នាក់ ក្រោយពីការបង្ក្រាបរួចមក យើងបានឲ្យពួកគាត់ចេញមកបង្ហាញខ្លួន និងអ្នកស្នើសុំ( ឪពុក )ចេញមកធ្វើការបញ្ជាក់ ពីការពិសោធន៍ DNA តើកូននោះពិតជាកូនមាន DNA ដូចដែរឬទេ។

មួយទៀតសម្រាប់ស្ត្រីពពោះចំនួន ១៨ នាក់ បើគេចេញមកបង្ហាញខ្លួន គឺពួកគាត់ពុំមានទោសអ្វីទេ។ ឥឡូវនេះ ស្ត្រីទាំងនោះកំពុងជួបការលំបាកថែទាំទារកក្នុងផ្ទៃ ព្រមទាំងសុខភាពផ្ទាល់របស់ពួកគាត់ទៀតផង។ ដូចនេះសុំឲ្យខាងអូស្ត្រាលី(អ្នកស្នើសុំ)ចេញមកទទួលខុសត្រូវ ចំពោះស្ត្រីពពោះទាំងនោះ ដែលពេលឆាប់ៗនេះ កូននឹងកើតចេញមកជាបន្តបន្ទាប់។

ចុងបញ្ចប់កិច្ចប្រជុំ លោកជំទាវបានមានប្រសាសន៍ សុំឲ្យខាងអគ្គសញ្ញាណកម្មជួយបំពេញបន្ថែម និងកែសម្រួលលើបែបបទនិងនីតិវិធីមួយចំនួន ដែលអង្គប្រជុំបានដាក់ជូន។ លោកជំទាវបានលើកបង្ហាញស្លាយពាក់ព័ន្ធបែបបទនីតិវិធី បណ្តោះអាសន្នសម្រាប់ការនាំទារក ចេញដោយការជួលពពោះជំនួស ទៅប្រទេសគោលដៅ ។ នឹងលើកយកនូវបែបបទ និងនីតិវិធីសម្រាប់អនុវត្តលើករណីដែលយើងកំពុងធ្វើដូចជាៈ

ក្រសួងស្ថាប័នទទួលខុសត្រូវ:

+ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ +ក្រសួងមហាផ្ទៃ

+អគ្គនាយកដ្ឋានអន្តោប្រវេសន៍ +ស្ថានទូតប្រទេសសាមី

+ស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ

**១.ឯកសាររបស់អ្នកស្នើសុំ**

-ពាក្យស្នើសុំ -រូបថត -ស្នាមក្រយៅដៃ -លិខិតថ្កោលទោស

-ស្ថានភាពគ្រួសារ -លិខិតបញ្ជាក់ទីលំនៅ ទ្រព្យសម្បត្តិ និងប្រាក់ចំណូល/ មុខរបរ

-លិខិតធានាអះអាង កិច្ចសន្យាក្នុងការចិញ្ចឹមថែទាំ

-សុពលភាពលិខិតឆ្លងដែន -លិខិតបញ្ជាក់ DNA

-របាយការណ៍បញ្ជាក់ពីការរីកលូតលាស់របស់កុមារ

**២.សំណុំលិខិតពីអ្នកពពោះ**

-លិខិតពេទ្យ( សម្រាលកូន ) -សបុត្រកំណើតកូន

-កិច្ចសន្យាពពោះ -ស្ថានភាពអ្នកពពោះ

-សាលក្រមផ្ទេរសិទ្ធអាណាព្យាបាលស្របច្បាប់ពីតុលាការ( ស្នើសុំសញ្ជាតិ )

**៣.សំណុំលិខិតរបស់ស្ថានទូត**

-កំណាត់ទូត បញ្ជូនលិខិតផ្លូវការ ដោយមានប្រថាប់ត្រាលើសំណុំឯកសារ( លិខិតអ្នកស្នើសុំ )

**៤.សំណុំលិខិតអនុញ្ញាតិរបស់ស្ថាប័នពាក់ព័ន្ធ**

**៥.អនុវត្តតាមនីតិវិធី**

-សំណុំលិខិតដាក់តាមស្ថានទូត -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងមហាផ្ទៃ

បែបបទនិងនីតិវិធី ជាបណ្តោះអាសន្ននេះ ទាមទារឲ្យបំពេញគ្រប់លក្ខខណ្ឌ និងប្រគល់សិទ្ធិជូនក្រសួងមហាផ្ទៃ ក្នុងការសម្រេចអនុញ្ញាត្តិ ឫពុំអនុញ្ញាត្តិ ដោយធ្វើការពិនិត្យយ៉ាងល្អិតល្អន់ ទៅលើលទ្ធភាព និងសមត្ថភាពរបស់ស្នើសុំអ្នកពពោះជំនួស និងក្រសួងស្ថាប័ន និងស្ថានទូតពាក់ព័ន្ធទទួលខុសត្រូវលើការអនុវត្ត។

កិច្ចប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោង ដប់ប្រាំពីរនិង ដប់ប្រាំនាទី ថ្ងៃខែឆ្នាំ ដដែល។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ទោ ឡឹក–សឿង

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ២០១៧

**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ត្រី.គង់ ពុទ្ធី

បានឃើញ
+ ទុកឯកសារ
15/02/2017